**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍**

**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់**

អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ សូមជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ជ្រាបថា យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្ដល់សិទ្ធិអាទិភាពដល់អ្នកសារព័ត៌មានទាំងអស់ទទួលបានការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ គ្រប់គ្នា ដូច្នេះ សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមេត្តាធ្វើបញ្ជីឈ្មោះថ្នាក់ដឹកនាំ បុគ្គលិក និងអ្នកព័ត៌មាននៅតាមអង្គភាពនីមួយៗឱ្យបានឆាប់បំផុតរួចផ្ញើមកអគ្គនាយដ្ឋានព័ត៌មាន និងសោតទស្សន៍ត្រឹមថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០ព្រឹក ដើម្បីអគ្គនាយកដ្ឋានបូកសរុបផ្ញើជូនក្រសួងសុខាភិបាល នៅវេលាម៉ោង ១២ថ្ងៃត្រង់ (ថ្ងៃដដែល)។

ដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សហការចាត់ចែងឱ្យបានឆាប់បំផុតតាមកាលកំណត់ខាងលើដោយក្ដីអនុគ្រោះ។

សូមបញ្ជូនបញ្ជីឈ្មោះតាមរយៈតេឡេក្រាម អ្នកទទួលឈ្មោះដូចខាងក្រោម៖

១. ផ្នែក កាសែត និងទស្សនាវដ្ដី៖ លោក សំ វិបុល ០៩៦ ៩៩៩៩ ៤៧៩។

២. ផ្នែក វិទ្យុ និងទូរទស្សន៍៖ លោក សួត លន់ ០១៦ ៦៦៦ ៤១១។

៣. ផ្នែក គេហទំព័រ៖ លោកស្រី សួយ សុវណ្ណនី ០៩៣ ៦៤៦ ៦០៦។

ថ្ងៃព្រហស្បតិ៍ ១២ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**អគ្គនាយក**

**ផុស សុវណ្ណ**